# ធម៌សម្រាប់ធ្វើឲ្យមានទីពឹង

នាថករណធម៌ ១០

នាថករណធម៌ គឺ ធម៌សម្រាប់ធ្វើឲ្យមានទីពឹង មាន ១០ យ៉ាង គឺ ៖

១. សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ
ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខ- សំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោស ស្ងួម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុង សិក្ខាបទទាំងឡាយ

២. ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេ-កល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្ម-ចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុ-បេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា
ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុងប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌មានសភាព ដូច្នោះ ភិក្ខុនោះក៏ចេះចាំច្រើន បានចាំទុក ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អ ដោយទិដ្ឋិ

៣. កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ
ភិក្ខុមានមិត្តល្អ មាន សម្លាញ់ល្អ ជាអ្នកពត់ខ្លួនតាមមិត្តសម្លាញ់ល្អ

៤. សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនី ភិក្ខុជាអ្នកប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយផ្ចិតផ្ចង់

៥. យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ
អំពើណា ដ៏ខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃមិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងអំពើនោះថា គួរធ្វើគួរចាត់ចែងបាន

៦. ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារប្បាមោជ្ជោ
ភិក្ខុជាអ្នកប្រាថ្នាធម៌ ពេញចិត្តនឹងការនិយាយធម៌ មានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម៌ និងអភិវិន័យ

៧. អារទ្ធវីរិយោ ហោតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ
ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវ ពួកអកុសលធម៌ និងញ៉ាំងពួកកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំង សង្វាតមាំមួន មិនដាក់ចុះនូវធុរៈ ក្នុង កុសលធម៌ទាំងឡាយ

៨. សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បយភេសជ្ជបរិក្ខារ តាមមានតាមបាន

៩. សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករលឹកឃើញ រលឹកតាមនូវអំពើ ដែលធ្វើយូរហើយផង
នូវពាក្យដែលនិយាយយូរហើយផង

១០. បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ភិក្ខុជាអ្នកមានប្រាជ្ញា
ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើត និងការរលត់នៃ ( ខន្ធ ) ដ៏ប្រសើរ ជាប្រាជ្ញាសម្រាប់ទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយ ប្រពៃ

ស្រង់ចាកសុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ៥១ ដល់ ៥៦,
ក្នុងបិដកលេខនេះ ដដែល ត្រង់ទំព័រ ១៩១ ព្រះមានព្រះភាគ ត្រាស់ហៅធម៌ទាំង ១០ នេះថា ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ( សាមគ្គិយា ឯកីភាវាយ សំវត្តន្តិ ) ។

និងក្នុងទំព័រ ៣៣០ ដល់ ៣៣៤ អានន្ទសូត្រ ព្រះអង្គត្រាស់ថា
ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ នេះ នឹងជាអ្នកចម្រើនលូតលាស់ ក្នុងធម្មវិន័យនេះ ( ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតិ ) ។

នាថករណធម៌ទាំង ១០ សរសេរបែបសង្ខេប ៖ សីលវា, ពហុស្សុតោ, កល្យាណមិត្តោ, សុវចោ, ទក្ខោ, ធម្មកាមោ, អារទ្ធវិរិយោ, សន្តុដ្ឋោ, សតិមា, បញ្ញវា

ពន្យល់

ឧច្ចាវចានិ កឹករណីយានិ

ពាក្យថា ឧច្ចាវចានិ កឹករណីយានិ ( អំពើដ៏ខ្ពស់ និងទាប ) បានដល់ ការងារដែលសួរគ្នីគ្នាយ៉ាងនេះថា ខ្ញុំនឹងធ្វើ ហើយទើបធ្វើ ។ បណ្តាការងារខ្ពស់ និងទាប ឈ្មោះថាការងារខ្ពស់ បានដល់ ការងារដូចជា ធ្វើចីវរ ជ្រលក់ចីវរ ជួសជុលព្រះចេតិយ ការងារដែលគប្បីធ្វើក្នុងរោងឧបោសថ ចេតិយ និងដើមពោធិព្រឹក្សជាដើម ។ ឈ្មោះថា ការងារទាប បានដល់ ការងារតូចៗ ដូចជា លាងបាត្រ លាបប្រេងជាដើម ។

ធម្មកាមោ

ពាក្យថា ធម្មកាម បានដល់ រមែងស្រឡាញ់ព្រះត្រៃបិដកពុទ្ធវចនៈ ។

អភិធម្មេ អភិវិនយេ

ពាក្យថា អភិធម្មេ អភិវិនយេ នេះ គប្បីជ្រាបពួក ៤ គឺ ធម៌ អភិធម៌ វិន័យ អភិវិន័យ ។ ក្នុងពួកទាំង ៤ នោះ ឈ្មោះថា ធម៌ បានដល់ ព្រះសុត្តន្តបិដក ឈ្មោះថា អភិធម៌ បានដល់ បករណ៍ទាំង ៧ ។ ឈ្មោះថា វិន័យ បានដល់ វិភង្គទាំង ២ [ ភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ ] ឈ្មោះថា អភិវិន័យ បានដល់ ខន្ធកៈ និងបរិវារ ។ ន័យម្យ៉ាងទៀត ទាំងសុត្តន្តបិដក ទាំងអភិធម្មបិដក ឈ្មោះថាធម៌ទាំងអស់ ។ មគ្គផល ឈ្មោះថា អភិធម៌ វិនយបិដកទាំងអស់ ឈ្មោះថា វិន័យ ការធ្វើការរម្ងាប់កិលេស ឈ្មោះថា អភិវិន័យ ៕

សូមអស់លោកអ្នកអនុមោទនា!

(ចប់)